ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ "ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007" នៅខេត្តសៀមរាប ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងលិខិតជូនដំណឹងលេខ៨៦៥ សជណ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការងារចាំបាច់

## ស ម្រេ ច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ "ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007" ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០០៧ នៅខេត្តសៀមរាបរួមមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិក កម្ពុជា | ប្រធាន |
| ២-ឯកឧត្តម | ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-ឯកឧត្តម | អ៊ុក ប្រាជ្ញា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៤-ឯកឧត្តម | សូ ភិរិន | អភិបាលខេត្តសៀមរាប | អនុប្រធាន |
| ៥-ឯកឧត្តម | សូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ - | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៦-ឯកឧត្តម | មាស សារិន | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |
| ៧-ឧត្តមសេនីយ៍ ឥត | សារ៉ាត់ | អគ្គលេខាធិការសហព័ន្ធកីឡាវាយកូនគោលកម្ពុជា | សមាជិក |
| ៨-ឯកឧត្តម | គីម គុណនឌ្ឍន៍ | អគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ៩-លោក | ហោ សារុន | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ | សមាជិក |
| ១០-លោកស្រី | ចៅស៊ីន គីរិយា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា | សមាជិក |
| ១១-ឧត្តមសេនីយ៍ ថោង | លីម | ប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១២-ឧត្តមសេនីយ៍ ញាណ | ចំរុង | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៣-លោក | ឡាយ ឫទ្ធី | នាយករងទីចាត់តយ និងរដ្ឋាករ | សមាជិក |
| ១៤-លោក | គុយ សុខ | ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |

**ប្រការ២ះ** ក្រុមការងារទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ដល់គណៈប្រតិភូ និងក្រុមកីឡាករអន្តរជាតិវាយកូនគោល នៅច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប និងច្រកទ្វារអន្តរជាតិផ្សេងៗទៀតទាំងពេលមកដល់ និងពេលនិវត្តន៍វិញ។
- ជួយសម្រួលបែបបទនៃការធ្វើដំណើរ និងបែបបទគយនៅតាមច្រកទ្វារអន្តរជាតិជូនគណៈប្រតិភូ និងក្រុមកីឡាករ។
- ជំរុញការស្ថាបនាផ្លូវជាតិលេខ ៦ សៀមរាប-ប៉ោយប៉ែត (កំណាត់ផ្លូវពីក្រុងសៀមរាបទៅកន្លែងវាយកូនគោល Phokeethra Country Club) ឱ្យបានទាន់ពេលវេលា។
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អនៅក្នុងពេលប្រកួតកីឡាវាយកូនគោលអាស៊ីលក្ខណៈអន្តរជាតិនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅលើទឹកដីខេត្តសៀមរាប។
- ធ្វើការផ្សព្វផ្សាយតាមបណ្តាញព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសតាមវិទ្យុ ទូរទស្សន៍ដើម្បីឱ្យទេសចរអន្តរជាតិ និងសាធារណជនបានយល់ជ្រួតជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលនេះ។
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរក និងទទួលជំនួយ និងការឧបត្ថម្ភនានាដល់កិច្ចដំណើរការសកម្មភាពនេះ។
- ជ្រើសរើសអ្នកជំនាញវាយកូនគោល (Professional Golfer) កម្ពុជាដើម្បីចូលរួម។
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃពិធីនេះជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ះ** ក្រុមការងារនេះត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអ្នករៀបចំកម្មវិធី (Organiser) និងផ្នែកឯកជនពាក់ព័ន្ធដើម្បីរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 ឱ្យទទួលបានជោគជ័យ។

**ប្រការ៤ះ** ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ មានសមាសភាពដូចខាងក្រោម :

១-លោក ហោ សារុន អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ ប្រធាន

២-លោក ពេញ ពន្លក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ អនុប្រធាន

៣-លោក ឡាយ ឫទ្ធី នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិកអចិន្ត្រៃយ៍

៤-លោក សំ ឌុន្នា អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅក្រសួងទេសចរណ៍ លេខាធិការ

៥-លោក ពីន ពិសិដ្ឋ អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក

៦-លោក ជាម សារ៉ាយ អនុប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ សមាជិក

៧-លោក គង់ សូលីដា នាយកខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក

៨-លោក សំ ស៊ីយ៉ាន ប្រធានអង្គភាពនគរបាលទេសចរណ៍ខេត្តសៀមរាប សមាជិក

៩-លោក ខ៊ូច សេខការ អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

១០-លោក នឹង មុន្នី នាយការិយាល័យនៃក្រសួងទេសចរណ៍ លេខាកត់ត្រា

១១-លោក ស៊ុយ សុផា នាយរងការិយាល័យនៃក្រសួងព័ត៌មាន សមាជិក

១២-លោក នួច ម៉ានី នាយរងការិយាល័យនៃក្រសួងទេសចរណ៍ សមាជិក

១៣-លោក ធន់ ចាន់នី អនុប្រធានការិយាល័យនៃមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

១៤-លោក សម ចន្ទីធីរៈ មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា សមាជិក

១៥-លោក ស៊ុំ សុណារត្ន មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ សមាជិក

១៦-លោក អ៊ុំ ចំនួនឧត្តមៈ មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ សមាជិក

**ប្រការ៥:** -ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។

-សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៦:** ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

**ប្រការ៧:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៤ខាងលើ ត្រូវទទួលអនុវត្តតាមសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-ឯកសារ-កាលប្បវត្តិ